# ភ្នំបុរល្អោង១២
# គំនូសឆ្កូតនៅស្រុកវាលវែង ខេត្តពោធិ៍សាត់

ភ្នំក្រវាញជាតំបន់ជួរភ្នំមួយនៃប្រទេសកម្ពុជា ដែលលាតសន្ធឹងក្នុងខេត្តមួយចំនួន ដូចជាខេត្តបាត់ដំបង ពោធិ៍សាត់ កោះកុង កំពង់ឆ្នាំង កំពង់ស្ពឺ ព្រះសីហនុ កំពត។ តំបន់នេះជាតំបន់ភ្នំ ព្រៃឈើ និងជីវចម្រុះដែលនៅមានអាថ៌កំបាំងជាច្រើន។ តាមរយៈផែនទីភូគព្ភសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាតំបន់នេះ ជាតំបន់ដែលស្ថិតនៅក្នុង ស័កទី២ ក្នុងសម័យ Jurassic និងCretaceous។[១] តំបន់នេះមានប្រជាជនរស់នៅតិចតួច ពិសេសគឺជនជាតិភាគតិច ដូចជាជនជាតិស្អូយ ជនជាតិព័រ ជងជាដើម។[២] ជនជាតិមួយចំនួនបានផ្លាស់ប្តូរទីលំនៅ ជាពិសេសក្នុងសម័យប៉ុលពត និងមកបច្ចុប្បន្ន ក៏ធ្វើឱ្យដាច់នៅទំនាក់ទំនង ហើយធ្វើឱ្យពត៌មានមួយចំនួនធំមានការបាត់បង់ ឬនៅសល់តិចតួច។ គំនូសឆ្កូតត្រូវបានរកឃើញនៅភ្នំបុរល្អោង១២ ស្ថិតនៅក្នុងឃុំ ក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់ នៅក្នុងច្រករបៀងជីវៈចម្រុះក្រវាញ។ គំនូសឆ្កូត គឺជាការគូសដោយវត្ថុរឹងអ្វីមួយទៅលើថ្មបង្កើតបានជាស្នាកស្នាមរូបភាពនៅលើថ្ម។ គេប្រទះឃើញគំនូសប្រភេទនេះ នៅតំបន់ភ្នំក្រវាញ ភ្នំគូលែន ពើងធ័ត្រ(ខេត្តបន្ទាយមានជ័យ) និងភ្នំព្រះស្រុកឱរ៉ាល់ខេត្តកំពង់ស្ពឺ។[៣]

សម្រាប់គំនូសទាំងនេះយើងបានចុះពិនិត្យកាលពីឆ្នាំ២០១៨ និងក្នុងឆ្នាំ២០២១នេះ ភ្នំនេះមានជាថ្មរដិបរដុប និងមានជាផ្ទាំងថ្មជាច្រើន បង្កើតបានជាពើងថ្ម និងរូងភ្នំតូចៗ ជាប្រភេទថ្មភក់ (រូបលេខ១)។ ថ្មទាំងឡាយនោះខ្លះក៏មានឈ្មោះហៅផ្សេងៗផងដែរ ដូចជាថ្មបាយសី (រូបលេខ២) ល្អាងយាងសក់ស ល្អាងតាបស ល្អាងគំនូរជាដើម។ គំនូសនេះត្រូវបានឃើញក្នុងរូងភ្នំតូចៗ ដែលមានជាច្រើនកន្លែង ខ្លះមានគំនូសតិចតួច និងខ្លះអាចចេញជារូបរៀងផ្សេងៗ ដូចជា៖

១.ល្អាងតាបស កើតឡើងដោយសារបណ្តុំថ្មធំ២ជាប់គ្នា ធ្វើឱ្យមានជារូងភ្នំ (រូបលេខ៣) អាចរស់នៅ ឬជ្រកបាន។ យើងឃើញមានគំនូសឆ្កូនតនៅក្នុងនោះផងដែរ (រូបលេខ៤-៥)។

---

[១] General Department of Mineral Resource,2010, Geological Map of Cambodia

[២] 2003 – 2004, BASELINE SOCIO-ECONOMIC STUDIES OF PHNOM AURAL WILDLIFE SANCTUARY, CAMBODIA, P.91

[៣] ធូ ២០១៨, កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ, ទំព័រ៤៨

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ

រូបលេខ២៤ផ្នែកខាងលើ ជួរទី១ និងជួរទី២ ជាគំនូសឆ្លូតដែលមើលហាក់ដូចជាបង្ហាញអំពីការរាប់លេខ ដែលនៅជួរទី១ និងទី២ មានចំនួនច្រើនជាង២០ទៅទៀតក្នុងមួយជួរ។ នៅផ្នែកខាងក្រោមនៃរូបលេខ២៤ និងរូបលេខ២៥ គេប្រើប្រាស់គំនូសឆ្លូតផងដែរ តែមានការខ្វែងខ្វាត់ជារូបអ្វីមួយ តែមើលមិនយល់។

២.ល្អាងយាយសក់ស (រូបលេខ២៦-៧) នេះជាឈ្មោះដែលអ្នករស់នៅក្នុងតំបន់នោះបានហៅ កន្លែងនេះមិនមានជាគំនូសឆ្លូតនោះទេ តែស្នាកស្នាមនៃថ្មធម្មជាតិ ហាក់ចេញជារូបមុខមនុស្ស ដូចជាភ្នែក និងមាត់។

៣.ល្អាងគំនូរ គេហៅទីតាំងដែលមានគំនូសឆ្លូតនោះថាជាល្អាងគំនូរដែរដូចគ្នានិងឈ្មោះល្អាងគំនូរនៅភ្នំក្រវាញ។ អ្នកខ្លះហៅល្អាងនេះថាល្អាងទ្វារ៨ ដោយហេតុថាមានច្រកចូលច្រើន(រូបលេខ២៨)។ ក្នុង (រូបលេខ២៩) យើងបែងចែកជាពីរសំខាន់ មួយផ្នែកជារូបមនុស្សពីរនាក់ រូបមនុស្សទី១ខាងឆ្វេងជារូបមនុស្ស ដែលមានភ្នែក២ ដែលគូសបញ្ឈិត និងស្នាមឆ្លូតត្រង់ដូចច្រមុះ ក្បាលមានកំប៉ោយសក់២ ដូចជាចង់ទីទុយ ដងខ្លួនគូសមានលក្ខណៈដូចជាអាវ ដៃទាំង២លើកឡើងទៅលើហាក់ដូចជាកាយវិការរាំ ជើងទាំង២ឈរ និងអាចមានលក្ខណៈដូចជាមនុស្សស្រី។ រូបមនុស្សទី២ មានកាយវិការប្រហាក់ប្រហែលគ្នានិងរូបមនុស្សទី១ ទម្រង់មុខអោនចុះក្រោម ដៃទាំងពីរលើកឡើងទៅលើ ដងខ្លួនមានស្នាកស្នាមគូសទទឹង មានលក្ខណៈដូចជាស្បៀកប៊ីង ជើងទាំងពីរមានម្រាម៥ ផ្នែកកណ្តាលត្រង់ចំនុចអវៈយវៈភេទ? គេឆ្លូតត្រង់វែង តើនេះអាចជានិម្មិតរូបនៃមនុស្សភេទប្រុសឬយ៉ាងណា? តែក្នុងកាយវិការនេះហាក់ដូចជាក្នុងពិធីអ្វីមួយ និងកំពង់រាំ។ នៅសងខាងនៃរូបមនុស្សទាំង២ មានស្នាមឆ្លូតជាចតុកោណដែលនៅខាងស្តាំមានខ្វែងជើងក្អែកកណ្តាលមាន៣រូប។ នៅខាងឆ្វេងនៃរូបមនុស្សមានចតុកោណ១ ដែលមានឆ្លូតជារូបចតុកោណខាងក្នុងនោះបន្តគ្នា៣ជាន់។ យើងមិនដឹងច្បាស់ថានេះជានិម្មិតរូបនៃអ្វីនោះទេ? ប៉ុន្តែសិល្បៈនៃការតុបតែងផ្ទះនៃ ជនជាតិមួយចំនួនដូចជានៅខេត្តរតនគិរី ដែលធ្វើអំពីឫស្សីនោះមានការតុបតែងលំអ មានលក្ខណៈជា៤ជ្រុងឬត្រីកោណ។ តាមពត៌មានរបស់ជនជាតិសួយ នៅតំបន់ទេទឹកពុះ នៅរវាងឆ្នាំ២០០៦ នៅពេលដែលខ្ញុំបានចុះប្រមូលពត៌មានខ្លះអំពីពួកគាត់ ក៏បានលើកឡើងអំពីផ្ទះបុរាណរបស់ពួកគាត់កាលពីមុន ធ្វើជញ្ជាំងអំពី

ឬស្សី និងមានក្បាច់លំអជាជ្រុងៗ និងមានពណ៌ផងដែរ។ ចំណែករូបលេខ១០ ជារូបមនុស្សម្នាក់ទៀតដែលធ្លាក់នៅផ្ទែកមួយទៀតនៅក្នុងល្អាងនោះផងដែរ។

៤.ល្អាងហ្មរដំរី ជាល្អាងធំមួយ ដែលតែងមានមនុស្សយកបាយសីមកសែននៅទីនោះ។ ហើយបាយសីទាំងនោះ គឺគេដាក់សែននៅផ្ទែកខាងលើនៃល្អាង។ ល្អាងហ្មរដំរី គឺមានដំណាលថា មានដំរីព្រៃមកត្រដុះខ្លួននៅទីនោះ ទើបមានផ្ទែកមួយនៅខាងស្តាំមានស្លាកស្នាមរលោង។ នៅក្បែរនោះក៏មានដុំថ្មជាច្រើនគរនៅទីនោះ ដែលតាមសំដីរបស់អ្នកភូមិនៅទីនោះ គឺថាមានដំរីមួយមកជាមួយហ្មបានស្រុត(ស្លាប់)នៅទីនោះ ហើយគេបានកប់ដោយយកថ្មមកគរ ក្រោយមកល្អាងនេះក៏ត្រូវបានហៅល្អាងហ្មរដំរី។ នៅពេលដែលមានអ្នកដែលមករកអនុផលព្រៃឈើ សត្វព្រៃ ឆ្លងកាត់ ឬសម្រាកនៅទីនេះតែងបោះដុំថ្ម១ដុំគរនៅទីនោះជាបន្តបន្ទាប់។

ទីតាំងភ្នំល្អាងបុរ១២ ជាទីតាំងដែលមានការចាប់អារម្មណ៍ និងទាក់ទាញលើស្នាដៃសិល្បៈដ៏កម្រមួយសម្រាប់ប្រទេសកម្ពុជា។ យើងមិនទាន់អាចកំណត់អាយុកាលបាននៅឡើយ ទោះយ៉ាងណាក៏យើងគិតថា ជាគំនូសដែលមានវ័យចំណាស់មួយដែរ។ នៅមានល្អាងជាច្រើនផ្សេងទៀតដែលយើងមិនទាន់បានឃើញនិងសិក្សា។ ទីតាំងនេះគួរមានការសិក្សាដោយអ្នកស្រាវជ្រាវឱ្យបានស៊ីជម្រៅបន្ថែម។

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១



រូបលេខ២



រូបលេខ៣

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៨



រូបលេខ២៩

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៦



រូបលេខ២៧



រូបលេខ២៨

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ៩



រូបលេខ១០



រូបលេខ១១

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ